ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០១៤

ឯកឧត្តមនាយករដ្ឋមន្ត្រី ហ៊ុន សែន

នាយករដ្ឋមន្ត្រីនៃព្រះរាជណាចក្រកម្ពុជា
ខុទ្ទកាល័យនាយករដ្ឋមន្ត្រី, ទីស្តីការគណរដ្ឋមន្ត្រី
ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
អ៊ីមែល៖ cabinet1b@camnet.com.kh

ឯកឧត្តមនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាទីរាប់អាន,

យើងខ្ញុំដែលមានចុះហត្ថលេខាខាងក្រោមនេះ មានសេចក្តីព្រួយបារម្ភយ៉ាងជ្រាលជ្រៅ ចំពោះការបន្តឃុំឃាំងមនុស្ស ២១ នាក់ ក្នុងចំណោមមនុស្ស ២៣ នាក់ ដែលត្រូវបានចាប់ខ្លួនក្នុងពេល និងបន្ទាប់ពីការបង្ក្រាបដោយហឹង្សាដោយកម្លាំងសន្តិសុខរដ្ឋ ប្រឆាំងកម្មកររោងចក្រកាត់ដេរដែលធ្វើកូដកម្ម និងអ្នកតវ៉ាដទៃទៀត ក្នុងទីក្រុងភ្នំពេញ នៅថ្ងៃទី ២ និង ៣ ខែមករា ឆ្នាំ ២០១៤ ។ យើងខ្ញុំ ក៏មានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំងបំផុតផងដែរ ដែលអាជ្ញាធរកម្ពុជា នៅមិនទាន់បានដកចេញបម្រាមទូទៅដាក់ប្រឆាំងការប្រមូលផ្តុំគ្នាជាសាធារណៈ ដោយរំលោភសិទ្ធិនៃការជួបជុំគ្នាដោយសន្តិវិធី ការសំដែងមតិ និងការធ្វើសមាគម តាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងរដ្ឋធម្មនុញ្ញកម្ពុជា ។

យើងខ្ញុំសូមអំពាវនាវឲ្យចាត់វិធានការដូចតទៅ ដើម្បីប្រតិបត្តិតាមកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋាភិបាល៖

1. ដោះលែងភ្លាម និងដោយគ្មានលក្ខខណ្ឌ ពួកអ្នកជាប់ឃុំទាំងអស់ដែលត្រូវបានចាប់ខ្លួនទាក់ទងទៅនឹងការធ្វើបាតុកម្ម និងភាពមិនស្ងប់ កាលពីពេលថ្មីៗនេះ ដែលត្រូវបានដាក់ឃុំដោយសារតែការប្រើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ពួកគេ រួមមានសិទ្ធិក្នុងការជួបជុំគ្នាដោយសន្តិវិធី ការសំដែងមតិ និងការធ្វើសមាគម,
2. ទម្លាក់ចោលភ្លាម និងដោយគ្មានលក្ខខណ្ឌ បទចោទប្រកាន់ទាំងអស់ប្រឆាំងមនុស្សដែលកំពុងត្រូវស៊ើបអង្កេត ទាក់ទងទៅនឹងការតវ៉ា គ្រាន់តែដើម្បីការប្រើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ពួកគេ រួមមាន សិទ្ធិនៃការជួបជុំគ្នាដោយសន្តិវិធី ការសំដែងមតិ និងការធ្វើសមាគម,
3. ស៊ើបអង្កេតជាបន្ទាន់ និងចាត់វិធានការផ្លូវច្បាប់សមស្រប ប្រឆាំងក្រុមហ៊ុនដែលបានបណ្តេញ ឬដាក់ទណ្ឌកម្មកម្មករ និងសមាជិកសហជីព

ដើម្បីជាការសងសឹកចំពោះការប្រើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ពួកគេ រួមមានសិទ្ធិទាក់ទងនឹងសកម្មភាពរបស់សហជីពផង,

4. ផ្តល់នូវការដោះលែងបណ្តោះអាសន្ន ស្របតាមច្បាប់អន្តរជាតិ ពួកអ្នកជាប់ឃុំនៅសេសសល់ទាំងប៉ុន្មាន ដែលបានដាក់ឃុំទាក់ទងនឹងការតវ៉ាក្នុងខែមករា និងធានាថាមេធាវីត្រូវទទួលបានដោយសេរី និងដោយពេញលេញ សំណុំរឿងនៃកូនក្តីរបស់ពួកគេ ដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទ័ណ្ឌ,
5. ធានាថាអ្នកណាក៏ដោយដែលត្រូវបានចោទប្រកាន់ទាក់ទងទៅនឹងការតវ៉ាក្នុងខែមករា ត្រូវទទួលបានការវិនិច្ឆ័យសេចក្តីយ៉ាងរហ័ស ត្រឹមត្រូវ និងជាសាធារណៈ នៅចំពោះមុខតុលាការមានសមត្ថភាព ឯករាជ្យ និងមិនលំអៀង ដោយគ្មានការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលក្នុងកិច្ចដំណើរការនៃការវិនិច្ឆ័យសេចក្តី,
6. ដកចេញជាបន្ទាន់បម្រាមមិនឲ្យធ្វើការប្រមូលផ្តុំគ្នាទាំងអស់ និងធានាដល់សិទ្ធិក្នុងការធ្វើការជួបជុំគ្នាដោយសន្តិវិធី ការធ្វើសមាគម និងការសំដែងមតិ,
7. ពិនិត្យឡើងវិញយ៉ាងប្រញាប់នូវច្បាប់ ក្រិត្យ អនុក្រិត្យ និង សេចក្តីសម្រេច ដែលមានបទបញ្ញត្តិដែលដាក់កំហិតដល់សិទ្ធិនៃសេរីភាពក្នុងការជួបជុំគ្នាដោយសន្តិវិធី ការធ្វើសមាគម និងការសំដែងមតិ រួមមានសិទ្ធិទាក់ទងទៅនឹងសកម្មភាព របស់សហជីព ដើម្បីនាំពួកគេឲ្យប្រព្រឹត្តស្របទៅនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការអនុវត្តល្អប្រសើរបំផុត, និង
8. ធានាថាអ្នកណាទទួលខុសត្រូវក្នុងការប្រើកម្លាំងហួសហេតុក្នុងអំឡុងពេលនៃការធ្វើការតវ៉ា ជាពិសេសពួកអ្នកទទួលខុសត្រូវក្នុងការសម្លាប់ ឬធ្វើឲ្យរបួស តាមរយៈនៃការប្រើកម្លាំងបែបនេះ រួមមានពួកអ្នកទទួលខុសត្រូវកើតចេញមកពីអាជ្ញាធរចេញបញ្ជា ត្រូវដាក់ទ័ណ្ឌកម្មខាងវិន័យសមស្រប ឬកាត់ទោសពីបទព្រហ្មទ័ណ្ឌ ។

យើងខ្ញុំសូមអបអរសាទរ ចំពោះការយកចិត្តទុកដាក់របស់លោកនាយករដ្ឋមន្ត្រី ចំពោះសេចក្តីបារម្ភដ៏ខ្លាំងក្លា និងកំពុងប្រព្រឹត្តទៅ នេះ ។

សូមលោកនាយករដ្ឋមន្ត្រីទទួលនូវសេចក្តីរាប់ដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ,

ហត្ថលេខា

ប្រាដ អាដាំ (Brad Adams) នាយកផ្នែកអាស៊ី នៃអង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW)

ស្កុត ណូវ៉ា (Scott Nova) នាយកប្រតិបត្តិ សមាគមសិទ្ធិកម្មករ (WRC)

លីនដា យ៉ង់ (Lynda Yang) នាយកប្រតិបត្តិ បណ្តាញសាមគ្គីភាពម៉ាគីណា (MSN)

អាន ដេកខឺរ (Anne Dekker) អ្នកសម្របសម្រួលនៃសេចក្តីអំពាវនាវបន្ទាន់ លេខាធិការក្រុមហ៊ុនសម្លៀកបំពាក់ស្អាតអន្តរជាតិ (CCC)

ហ្វាមី ប៉ានីមប៊ែ (Fahmi Panimberg) អ្នកសម្របសម្រួលកម្មវិធី
មជ្ឈមណ្ឌលធនធានតាមដានអាស៊ី (AMRC)

ជូឌី ហ្គីហាត (Judy Gearhart) នាយកប្រតិបត្តិ វេទិកាសិទ្ធិការងារអន្តរជាតិ (ILRF)

អេស្តេឡា រ៉ាមីរ៉េ (Estela Ramirez) ប្រធានសកល អ្នកទទួលខុសត្រូវសម្ព័ន្ធសហជីពសម្រាប់យីហោ

ការីម ឡាហ៊ីតហ្ស៊ី (Karim Lahidji) ប្រធាន សហព័ន្ធសិទ្ធិមនុស្សអន្តរជាតិ (FIDH)

អ៊ីហ្សាបែល អារ៉ាដុន (Isabelle Arradon) នាយករងនៃអាស៊ី-ប៉ាស៊ីហ្វិក
អង្គការលើកលែងទោសអន្តរជាតិ-លេខាធិការដ្ឋានអន្តរជាតិ

ប្រ៊ីតតីស អេតម៉ាន់ (Brittis Edman) នាយកផ្នែកអាស៊ីអគ្នេយ៍ អ្នកការពារសិទ្ធិពលរដ្ឋ

ស៊ូ ហ្គូណាវ៉ាដេណា-វ៉ុក (Sue Gunawardena-Vaughn) បណ្ឌិត នាយកផ្នែកអាស៊ីអគ្នេយ៍
គេហដ្ឋានសេរីភាព (Freedom House)

អ៊ីវ៉ើលីន បាឡេ-សេរ៉ាណូ (Evelyn Balais-Serrano) នាយកប្រតិបត្តិ វេទិកាអាស៊ី សម្រាប់សិទ្ធិ
មនុស្ស និងការអភិវឌ្ឍន៍ (Forum-Asia)